**ការរាយការណ៍អំពីកម្មវិធីជំនួយនៃឱកាសផ្ដល់មូលនិធិឆ្នាំ 2023 របស់កម្មវិធី Inclusive Grant Program**

ជូនចំពោះអ្នកទទួលជំនួយ

ប្រហែលខែមីនា ឆ្នាំ 2023 អាជីវកម្មរបស់អ្នកបានទទួលឱកាសផ្ដល់មូលនិធិឆ្នាំ 2023 នៃកម្មវិធី Inclusive Grant Program របស់ Massachusetts Growth Capital Corporation (MGCC) ដែលអនុញ្ញាតឱ្យប្រើប្រាស់មូលនិធិចំគោលដៅក្នុងបំណងជួយដល់អាជីវកម្មនានាក្នុងអំឡុងពេលជំងឺរាតត្បាត។

អាជីវកម្មរបស់អ្នកគួរតែបំពេញរបាយការណ៍ ដែលអាចចូលប្រើបាននៅក្នុងគណនី Submittable របស់អ្នក ដើម្បីកត់ត្រាលទ្ធផល និងអត្ថប្រយោជន៍ដែលអាចធ្វើទៅបានតាមរយៈមូលនិធិជំនួយរបស់ MGCC។

ការដាក់ស្នើរបាយការណ៍នឹងបិទនៅ ***ថ្ងៃទី 4 ខែមីនា ឆ្នាំ 2026***។

ការបំពេញរបាយការណ៍នេះ គឺជាលក្ខខណ្ឌមួយនៃការទទួលបានពានរង្វាន់ជំនួយនៃឱកាសផ្ដល់មូលនិធិឆ្នាំ 2023 របស់កម្មវិធី Inclusive Grant Program។ ការខកខានមិនបានផ្ដល់ព័ត៌មានដែលបានស្នើសុំ នឹងធ្វើឱ្យអាជីវកម្មរបស់អ្នកបាត់បង់សិទ្ធិសម្រាប់ឱកាសផ្ដល់មូលនិធិនានានាពេលអនាគតជាមួយ MassDevelopment។ MassDevelopment ក៏អាចនឹងទាមទារឱ្យមានការសងមូលនិធិជំនួយត្រឡប់មកវិញផងដែរ ប្រសិនបើអាជីវកម្មរបស់អ្នកមិនផ្ដល់របាយការណ៍ដែលបានស្នើសុំ។ សូមមើលផ្នែក 4A និង 7 នៃ កិច្ចព្រមព្រៀងជំនួយនៃឱកាសផ្ដល់មូលនិធិឆ្នាំ 2023 របស់កម្មវិធី Inclusive Grant Program។

MGCC ត្រូវបានបញ្ចូលគ្នាដោយច្បាប់ទៅក្នុងផ្នែកមូលធនកំណើន នៅ MassDevelopment ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 2025។ MassDevelopment បានទទួលបន្តនូវកម្មវិធីជំនួយ និងកិច្ចព្រមព្រៀងដែលមានស្រាប់របស់ MGCC។

ប្រសិនបើអ្នកមានបញ្ហាបច្ចេកទេសណាមួយនៅលើ Submittable សូមចូលទៅកាន់មជ្ឈមណ្ឌលជំនួយ ឬដាក់ស្នើសំបុត្រស្នើសុំការគាំទ្រ។

ដោយក្ដីគោរពរាប់អាន

MassDevelopment

---

**មានបញ្ហាក្នុងការស្វែងរកទម្រង់បែបបទរបាយការណ៍មែនទេ?**

1. ដើម្បីស្វែងរកទម្រង់បែបបទដែលបានស្នើសុំ សូមឡុកចូលទៅក្នុងគណនីរបស់អ្នកដោយប្រើប្រាស់អាសយដ្ឋានអ៊ីមែលដែលអ្នកបានប្រើដើម្បីដាក់ស្នើដំបូង៖ [ឡុកចូលទៅកាន់គណនី Submittable]
2. សូមប្រាកដថាអ្នកស្ថិតនៅលើទំព័រ Submissions (ការដាក់បញ្ជូន) បន្ទាប់មកចូលទៅកាន់ផ្ទាំង "All Submissions (ការដាក់បញ្ជូនទាំងអស់)"។ បន្ទាប់មក ចុចលើចំណងជើង (ឈ្មោះអាជីវកម្ម) នៃការដាក់បញ្ជូនរបស់អ្នក។
3. ប្រសិនបើអ្នកមិនឃើញការដាក់ស្នើដែលអ្នកកំពុងស្វែងរកទេ សូមប្រាកដថាអ្នកបានឡុកចូលទៅកាន់ Submittable ជាមួយនឹងអាសយដ្ឋានអ៊ីមែលដែលអ្នកបានប្រើដើម្បីបង្កើតគណនីរបស់អ្នក។ អ្នកអាចពិនិត្យមើលបាន ដោយចុចលើអក្សរដំបូងនៃឈ្មោះរបស់អ្នក នៅជ្រុងខាងស្ដាំផ្នែកខាងលើ។
4. បន្ទាប់មក ចុចលើផ្ទាំង "Forms (ទម្រង់បែបបទ)" និងប៊ូតុង "Open (បើក)" ឬ "Continue (បន្ត)" ពណ៌ខៀវ ដើម្បីមើលទម្រង់បែបបទដែលមានចំណងជើងថា "**របាយការណ៍ជំនួយនៃឱកាសផ្ដល់មូលនិធិឆ្នាំ 2023 របស់កម្មវិធី Inclusive Grant Program**" ហើយអនុវត្តតាមការណែនាំ។
5. សូមប្រាកដថាអ្នកបានដាក់ស្នើទម្រង់បែបបទរបស់អ្នក នៅពេលដែលអ្នកបានបំពេញរួចរាល់។